# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ភាគរយក្នុងការចាក់ផ្សាយព័ត៌មានសមធម៌សំរាប់គណបក្សនយោបាយ

ភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨

ព័ត៌មានសមធម៌ ដែលជាកម្មវិធីព័ត៌មានស្តីអំពីការបោះឆ្នោតក្រោមការសហការរវាងអង្គការ UNDP និងទូរទស្សន៍ជាតិកម្ពុជា សូមប្រកាសនូវភាគរយក្នុងការចាក់ផ្សាយសំរាប់ផ្តល់ជូនដល់គណបក្សនយោបាយនានា ដើម្បីធានាអោយបាននូវការផ្សព្វផ្សាយពីសកម្មភាពយុទ្ធនាការឃោសនាបោះឆ្នោតមួយដែលមាន យុត្តិធម៌ និងតុល្យភាព ក្នុងកំឡុងពេលរៀបចំខ្លួនសំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលនឹង ប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ។

ក្នុងកំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោតចាប់ពីថ្ងៃទី២៦ ខែមិថុនា ដល់ថ្ងៃទី២៥ ខែកក្កដា ព័ត៌មានសមធម៌នឹងចាក់ផ្សាយពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ក្រោយព័ត៌មានក្នុងស្រុក ដោយធ្វើការសង្ខេបព្រឹត្តការណ៍សរុបនៅថ្ងៃសៅរ៍ ហើយនិងចាក់ផ្សាយឡើងវិញនៅថ្ងៃបន្ទាប់ក្រោយព័ត៌មានថ្ងៃត្រង់នៅលើកញ្ចក់ទូរទស្សន៍ជាតិកម្ពុជា ។

ភាគរយក្នុងការចាក់ផ្សាយព័ត៌មានសមធម៌ ដែលកំនត់ដោយ UNDP និង ទូរទស្សន៍ជាតិកម្ពុជាត្រូវបានទទួលការគាំទ្រដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## រូបមន្តមានលក្ខណៈដូចខាងក្រោយ៖

| គណបក្សនយោបាយ | ភាគរយក្នុងការចាក់ផ្សាយសរុប |
|---|---|
| គណបក្សប្រជាជន | ២០% |
| គណបក្សសមរង្ស៊ី | ១៣% |
| គណបក្សហ៊្វុនស៊ិនប៉ិច | ១១% |
| គណបក្សនរោត្តមរណឫទ្ធិ | ៩% |
| គណបក្សប្រជាធិបតេយ្យខ្មែរ | ៩% |
| គណបក្សហង្សដារ៉ាចលនាប្រជាធិបតេយ្យ | ៩% |
| គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ៩% |
| គណបក្សសិទ្ធិមនុស្ស | ៨% |
| គណបក្សខ្មែរសាធារណៈរដ្ឋ | ៥% |

| | |
|---|---|
| គណបក្សខ្មែរឈប់ក្រ | ៤% |
| គណបក្សសង្គមយុត្តិធម៌ | ៣% |

ឆ្នាំនេះរូបមន្តក្នុងការកំនត់ភាគរយត្រូវបានគណនាតាមរបៀបខុសពីលើកមុន ដោយអោយតំលៃខ្លាំងទៅលើចំនួនបេក្ខជនឈរឈ្មោះរបស់គណបក្សនយោបាយនីមួយៗក្នុងការបោះឆ្នោត ឆ្នាំ២០០៨ ជាជាងលទ្ធផលរបស់គណបក្សពីការបោះឆ្នោតលើកមុនៗ។ ៨០% នៃភាគរយក្នុងការចាក់ផ្សាយសរុបត្រូវបានបែងចែកទៅអោយគណបក្សនយោបាយតាមមធ្យមភាគ ដោយផ្អែកលើចំនួនបេក្ខជនឈរឈ្មោះសំរាប់អាសនៈទាំង១២៣ របស់គណបក្សនយោបាយនីមួយៗ ។ ចំនែក ២០%ត្រូវបានបែងចែកដល់រាល់គណបក្សនយោបាយដែលមានលទ្ធផលក្នុងការបោះឆ្នោតក្នុងឆ្នាំ២០០៣ និងឆ្នាំ២០០៧ ដោយផ្អែកលើចំនួនអាសនៈ និងចំនួនសន្លឹកឆ្នោតបានការដែលគេទទួលបាន។ កំរិតកំហុសគឺ +/–៣%។

គណបក្សដែលមិនមានបេក្ខជនឈរឈ្មោះសំរាប់អាសនៈទាំងអស់ ទទួលបានភាគរយទៅតាមមធ្យមភាគនៃ៨០% ហើយការបែងចែកនេះ បានផ្តល់ម៉ោងផ្សាយដល់គណបក្សទាំងនេះ ច្រើនជាងកាលពីលើកមុន ដែលកម្មវិធីធ្លាប់បានផ្តល់អោយ ។

ដោយអនុវត្តតាមវិធីខាងលើ ការផ្តោតទៅលើលទ្ធផលពីអតីតកាល និងបុព្វសិទ្ធិរបស់គណបក្សកាន់អំណាចត្រូវបានកាត់បន្ថយ ហើយវាបានផ្តល់ឱកាសនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ កាន់តែច្រើនដល់គណបក្សប្រឆាំង និងគណបក្សថ្មីៗនានា ដែលមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយតិចនៅរយៈពេលចន្លោះរវាងការបោះឆ្នោតនិមួយៗ ។

លក្ខណៈពិសេសរបស់ព័ត៌មានសមធម៌ គឺកម្មវិធីនឹងប្រកាសជាសាធារណៈពីចំនួនភាគរយនៃ ម៉ោងផ្សាយដែលបានបែងចែកសំរាប់គណបក្សនិមួយៗ តាមគោលការណ៍សមធម៌ ។ មជ្ឈដ្ឋានពាក់ព័ន្ធសំខាន់ៗនិងអ្នកបោះឆ្នោតអាចតាមដានដោយខ្លួនឯងថាតើព័ត៌មានសមធម៌គោរពតាមរូបមន្តដែលខ្លួនគិតថានឹងផ្តល់ភាពយុត្តិធម៌ និងតុល្យភាព ក្នុងការរាយការណ៍ដោយផ្អែកលើប្រវត្តិពីអតីតកាល ស្ថានភាពបច្ចុប្បន្ន និងទំហំរបស់គណបក្ស ។

ការគណនាតាមរូបមន្តលំអិតដែលមានតំលៃជាទសភាព នឹងត្រូវដាក់បង្ហាញនៅលើគេហ៍ទំព័រ របស់កម្មវិធី www.equitycam.tv ។ ក្នុងកំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោតនាឡិកាលើ គេហ៍ទំព័រនឹងបង្ហាញពីពេលវេលាជានាទី ដែលបានបែងចែកប្រចាំថ្ងៃសំរាប់គណបក្សនានា ។ រូបមន្តគិតជាភាគរយនៅក្នុងតារាងខាងលើ គឺជាពេលវេលាសរុបសំរាប់រដូវកាលយុទ្ធនាការឃោសនាបោះឆ្នោតទាំងមូល ។

សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង លោក **ម៉ែន គីមសេង** តាមទូរស័ព្ទលេខ ០១២ ៥៥៥ ៦០៥ ឬតាមរយៈអ៊ីម៉េល men.kimseng@undp.org ឬទាក់ទង លោកស្រីបណ្ឌិត **ដាហ្វនី ស្គីលឡែន** តាមរយៈអ៊ីម៉េល daphne.skillen@undp.org ៕